# សុន្ទរកថារបស់លោក ណាកាជីម៉ា យ៉ូហេ
# លេខាទី២ នៃស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីប្រគល់ឧបករណ៍បរិក្ខារវេជ្ជសាស្ត្រនៅមន្ទីរពេទ្យបង្អែកបាកាន ខេត្តពោធិ៍សាត់

ថ្ងៃទី០៧ ខែ តុលា ឆ្នាំ ២០១៦

- **សូមគោរព ឯកឧត្តមសាស្ត្រាចារ្យ ផេង ហួត រដ្ឋលេខាធិការក្រសួងសុខាភិបាល**
- **សូមគោរព លោកជំទាវ ជុក សុជានី អភិបាលរងនៃគណៈអភិបាលខេត្តពោធិ៍សាត់**
- **សូមគោរព លោកវេជ្ជបណ្ឌិត ខូយ ឌី ប្រធានមន្ទីរសុខាភិបាលខេត្តពោធិ៍សាត់**
- **សូមគោរព លោក សៅ ដាឿន អភិបាលនៃគណៈអភិបាលស្រុកបាកាន**
- **សូមគោរព អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានមកចូលរួមពិធីប្រគល់ឧបករណ៍បរិក្ខារវេជ្ជសាស្ត្រនៅមន្ទីរពេទ្យបង្អែកបាកាន ខេត្តពោធិ៍សាត់នេះ ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមសាស្ត្រាចារ្យ ផេង ហួត** រដ្ឋលេខាធិការក្រសួងសុខាភិបាល។ ជាបឋម ខ្ញុំសូមសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅចំពោះ**ឯកឧត្តមសាស្ត្រាចារ្យ ផេង ហួត** ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ដែលបានអញ្ជើញមកចូលរួមក្នុងពិធីនេះ។

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងនៅក្នុងការកសាងឡើងវិញ និងការអភិវឌ្ឍប្រទេសរបស់ខ្លួន ហើយក៏បានធ្វើអោយសម្រេចនូវអត្រាកំណើនសេដ្ឋកិច្ចខ្ពស់បំផុតរបស់ខ្លួន ស្មើនឹងបណ្តាប្រទេសកំពុងរីកចំរើនក្នុងតំបន់អាស៊ាន។ នៅក្នុងវិស័យសុខាភិបាល ទាំងបរិមាណនិងគុណភាពមានភាពប្រសើរឡើងយ៉ាងខ្លាំងផងដែរ តាមរយៈកិច្ចសហប្រតិបត្តិការរវាងក្រសួងសុខាភិបាល និងសហគមន៍អន្តរជាតិ។

ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនេះ ជប៉ុន ក៏បានជួយបំពាក់នូវឧបករណ៍បរិក្ខារវេជ្ជសាស្ត្រមួយចំនួនដល់មន្ទីរពេទ្យបង្អែកបាកាននៅក្នុងគម្រោងនេះផងដែរ។ នៅមន្ទីរពេទ្យនេះ ចំនួននៃអ្នកជម្ងឺមានការកើនឡើងយ៉ាងខ្លាំង និងតម្រូវការសម្រាប់ការថែទាំវេជ្ជសាស្ត្រក៏កាន់តែច្រើនផងដែរនៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ មុនពេលអនុវត្តគម្រោងនេះ ម៉ាស៊ីនថតដោយកាំរស្មីអ៊ិច និងម៉ាស៊ីនអេកូសាស្ត្រចាស់ មិនអាចដំណើរការអស់រយៈពេលជាច្រើនឆ្នាំមកហើយ ហើយកៅអីសម្រាប់ទន្តពេទ្យចាស់ ក៏មានការខ្វះខាតនូវមុខងារសំខាន់ៗសម្រាប់ដំណើរការផងដែរ។ កាលពីមុន មន្ទីរពេទ្យបង្អែកនេះ ក៏មិនធ្លាប់មានម៉ាស៊ីនវិភាគឈាម និងម៉ាស៊ីនវិភាគគីមី។ ហេតុនេះ វាមានផលលំបាកសម្រាប់បុគ្គលិកមន្ទីរពេទ្យដើម្បីពង្រឹងការធ្វើរោគវិនិច្ឆ័យ និងបំពេញតាមតម្រូវការរបស់អ្នកជម្ងឺ។ ឧបករណ៍បរិក្ខារវេជ្ជសាស្ត្រថ្មីទាំងនេះ ត្រូវបានឧបត្ថម្ភក្រោមជំនួយឧបត្ថម្ភឥតសំណងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិរបស់ជប៉ុន ដែលនឹងអនុញ្ញាតអោយអ្នកជម្ងឺកាន់តែច្រើនឡើងទទួលបានការព្យាបាលសុខភាពកាន់តែល្អប្រសើរជាងមុន។ យើងសង្ឃឹមថា គម្រោងនេះ នឹងរួមចំណែកជួយកែលម្អសេវាសុខភាពនៅក្នុងតំបន់នេះផងដែរ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឧបករណ៍បរិក្ខារវេជ្ជសាស្ត្រថ្មីនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវល្អ និងប្រើប្រាស់បានយូរអង្វែងប្រកបដោយប្រសិទ្ធិភាព ដើម្បីទុកជានិមិត្តរូបនៃទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**